**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ...៤៣៧...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលការិយាល័យបញ្ជូនសារ និងបំព័ន្ធអក្ខរៈ ចំណុះនាយកដ្ឋានផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន ទៅជាជំនាញគ្រប់គ្រងបញ្ជូនសារ និងបំព័ន្ធអក្ខរៈ នៃមជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកែសម្រួលមាត្រា៤ និងមាត្រា១៣ នៃអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១.-**

ត្រូវបានកែសម្រួលការិយាល័យបញ្ជូនសារ និងបំព័ន្ធអក្ខរៈចំណុះនាយកដ្ឋានផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន ទៅជាជំនាញគ្រប់គ្រងបញ្ជូនសារ និងបំព័ន្ធអក្ខរៈ នៃមជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម មានឋានៈស្មើនឹងនាយកដ្ឋាន។

**មាត្រា២.-**

តួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងក្របខ័ណ្ឌចាត់តាំងរបស់ជំនាញគ្រប់គ្រងបញ្ជូនសារ និងបំព័ន្ធអក្ខរៈ អាស្រ័យដោយក្រសួងការពារជាតិកំណត់។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ច័ន្ទ...៨...កើត ខែ...បុស្ស...ឆ្នាំរកា ព.ស២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី...២៥...ខែ...ធ្នូ...គ.ស ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ២៣២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ធ្នូ គ.ស ២០១៧
រចនាសម្ព័ន្ធចាត់តាំងជំនាញគ្រប់គ្រងបញ្ជូនសារ និងបំភ័ន្តអក្ខរៈ

